## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ២៩២ ឥ.ស.រ កសក ប

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម គណៈកម្មការវាយតម្លៃឯកសារដេញថ្លៃទំនិញ និងសំណង់ និងគណៈកម្មការវាយតម្លៃជ្រើសរើសទីប្រឹក្សាសម្រាប់ការអនុវត្តកម្មវិធីអភិវឌ្ឍន៍ពាណិជ្ជកម្មស្រូវដែលធន់នឹងអាកាសធាតុក្នុងក្របខ័ណ្ឌហិរញ្ញប្បទាន សហប្រតិបត្តិការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជ- រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ឱ្យទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១._**

ត្រូវបានបង្កើត ១. គណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម ២. គណៈកម្មការវាយតម្លៃឯកសារដេញថ្លៃទំនិញ និងសំណង់ និង ៣. គណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សា ស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពគ្រប់គ្រងកម្មវិធីថ្នាក់ជាតិសម្រាប់អនុវត្តកម្មវិធីអភិវឌ្ឍន៍ពាណិជ្ជកម្មស្រូវដែលធន់នឹងអាកាសធាតុ។

**ប្រការ២._**

គណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្ម មានសមាភាពដូចខាងក្រោម៖

**ក. គណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្មកម្រិតធំ**

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ម៉ម អំណាត់** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២. | ឯកឧត្តម **គិត សេង** | នាយកគ្រប់គ្រងកម្មវិធី | សមាជិក |
| ៣. | ឯកឧត្តម **ខិន ឆាយ** | នាយករងគ្រប់គ្រងកម្មវិធី | សមាជិក |
| ៤. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |
| ៥. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |

**ខ. គណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្មកម្រិតមធ្យម**

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **គិត សេង** | នាយកគ្រប់គ្រងកម្មវិធី | ប្រធាន |
| ២. | ឯកឧត្តម **ខិន ឆាយ** | នាយករងគ្រប់គ្រងកម្មវិធី | សមាជិក |
| ៣. | លោក **អោម ពៅ្យ** | អ្នកសម្របសម្រួលកម្មវិធី | សមាជិក |
| ៤. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |
| ៥. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |

**គ. គណៈកម្មការត្រួតពិនិត្យកិច្ចលទ្ធកម្មកម្រិតតូច**

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ខិន ឆាយ** | នាយករងគ្រប់គ្រងកម្មវិធី | ប្រធាន |
| ២. | លោក **អោម ពៅ្យ** | អ្នកសម្របសម្រួលកម្មវិធី | សមាជិក |
| ៣. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |

**ប្រការ៣._**

គណៈកម្មការវាយតម្លៃឯកសារដេញថ្លៃទំនិញ និងសំណង់ មានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. | លោកស្រី **អ៊ុន សុគា** | មន្ត្រីទទួលបន្ទុករដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ | ប្រធាន |
| ២. | លោក **ឃី រតនៈ** | មន្ត្រីទទួលបន្ទុកគ្រប់គ្រងកិច្ចសន្យា | សមាជិក |
| ៣. | លោក **ពេជ ផល្លី** | មន្ត្រីទទួលបន្ទុកបច្ចេកទេសដំណាំស្រូវ | សមាជិក |

**ប្រការ៤._**

គណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សា មានសមាសភាពដូចខាងក្រោម ៖

**ក. គណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សាកម្រិតធំ**

| | | | |
|---|---|---|---|
| ១. | លោក **ញ៉ែម ចាន់** | មន្ត្រីទទួលបន្ទុកផែនការ និងការអនុវត្តគម្រោង | ប្រធាន |
| ២. | លោក **អំ តិរម្យ** | មន្ត្រីទទួលបន្ទុកគ្រប់គ្រងធនធានដី | សមាជិក |
| ៣. | លោក **ស៊ុន ទ្រី** | មន្ត្រីទទួលបន្ទុកការងារផ្សព្វផ្សាយកសិកម្ម | សមាជិក |

៤. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៥. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

**ខ. គណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សាកម្រិតមធ្យម**

| | | | |
|---|---|---|---|
| ១. | លោក **ញ៉េម ចាន់** | មន្ត្រីទទួលបន្ទុកផែនការ និងការអនុវត្តគម្រោង | ប្រធាន |
| ២. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |
| ៣. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |
| ៤. | លោក **ជា សុវណ្ណឌីណា** | មន្ត្រីទទួលបន្ទុកបច្ចេកវិទ្យាមុន និងក្រោយពេលប្រមូលផល | សមាជិក |
| ៥. | លោក **ស៊ុន ទ្រី** | មន្ត្រីទទួលបន្ទុកការងារផ្សព្វផ្សាយកសិកម្ម | សមាជិក |

**គ. គណៈកម្មការវាយតម្លៃឯកសារជ្រើសរើសទីប្រឹក្សាកម្រិតតូច**

| | | | |
|---|---|---|---|
| ១. | លោក **ញ៉េម ចាន់** | មន្ត្រីទទួលបន្ទុកផែនការ និងការអនុវត្តគម្រោង | ប្រធាន |
| ២. | លោក **ស៊ុន ទ្រី** | មន្ត្រីទទួលបន្ទុកការងារផ្សព្វផ្សាយកសិកម្ម | សមាជិក |
| ៣. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | សមាជិក |

**ប្រការ៥._**

ប្រធានអង្គភាពគ្រប់គ្រងកម្មវិធីថ្នាក់ជាតិ អាចអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធមកចូលរួមជាសមាជិកគណៈកម្មការណាមួយ តាមការចាំបាច់។

**ប្រការ៦._**

សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៧._**

អគ្គលេខាធិការ អគ្គាធិការ ប្រធានអង្គភាពគ្រប់គ្រងកម្មវិធីថ្នាក់ជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៣កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ០៤ ខែ កក្កដា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ